ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៨៧៣
ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩
សញ្ញាណនៃរឿងក្តី៖ លែងលះ
សាលក្រមលេខ ៖ ០៨ "ឈ"
ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

- បានបញ្ចប់ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី២០ ខែ មករា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក ក្នុងបន្ទប់សវនាការលេខ០២ អគារA នៃសាលាដំបូងខេត្តសៀមរាប ។

- កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០

ដោយមានសមាសភាព

**ចៅក្រម**

-លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តសៀមរាប

កម្មវត្ថុនៃពាក្យបណ្ដឹង : លែងលះប្តី ។

-ភាគីដើមចោទឈ្មោះ [redacted] ស៊ីណាន ភេទស្រី អាយុ ៣១ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នភូមិ[redacted] មុខរបរៈ នគរបាល ។ អមដោយលោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ។

- ភាគីចុងចម្លើយឈ្មោះ [redacted] បូរិន ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] ។

**អង្គហេតុ និងចំណុចវិវាទ**

អង្គហេតុ៖

ដើមចោទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] បូរិន តាំងពីឆ្នាំ២០០៧ មកម្លេះ ដោយរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយសំបុត្រអាពាហ៍ពិពាហ៍លេខ ២៧ សៀវភៅអាពាហ៍ពិពាហ៍លេខ១/២០១៧ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ។ ក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាតែងតែមានភាពរកាំរកូស មិនចុះសម្រុងគ្នា ដោយភាគីចុងចម្លើយចូលចិត្តផឹកស៊ី និងបានប្រើអំពើហិង្សាមកលើដើមចោទជាប្រពន្ធ មិនត្រឹមតែប៉ុណ្ណោះគាត់តែងតែធ្វើបាបផ្លូវចិត្តដើមចោទ មិនត្រឹមតែប៉ុណ្ណោះចុងចម្លើយមិនដែលបានរកស៊ីចិញ្ចឹមកូន ចុងចម្លើយចូលចិត្តលេងល្បែងស៊ីសង ។ ក្នុងអំឡុងពេលរៀបការជាមួយគ្នារវាងដើមចោទ និងចុងចម្លើយ មិនមានទ្រព្យសម្បត្តិរួមអ្វីនោះ គឺមានតែកូនបីនាក់នោះទេ ។

ការទាមទាររបស់ដើមចោទ ៖

ដើមចោទប្ដឹងសុំឲ្យតុលាការចេញសាលក្រមសម្រេចដូចតទៅ ៖

១-សុំលែងលះពីចុងចម្លើយពីចុងចម្លើយឈ្មោះ [redacted] បូរិន ពីពេលនេះតទៅ ។



Scanned with CamScanner

២-ប្រគល់សិទ្ធអំណាចមេបាលើកូន ០៣នាក់ មកឲ្យដើមចោទ ៖

ក. កូនទី១ឈ្មោះ [redacted] គីមឡាង ភេទស្រី កើតថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៨

ខ. កូនទី២ឈ្មោះ [redacted] វ៉ាន់នីឡា ភេទស្រី កើតថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤

គ.កូនទី៣ឈ្មោះ [redacted] លីម៉ី ភេទស្រី កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥

៣. ស្នើសុំឲ្យចុងចម្លើយបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព រហូតដល់កូនគ្រប់និតិភាព។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទរ៉ាប់រងបង់តែម្នាក់ឯង ។

## សេចក្តីថ្លែងការណ៍របស់ភាគី

### ការអះអាងរបស់ដើមចោទ

- ដើមចោទឈ្មោះ [redacted] ស៊ីណាន បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] បូរិន តាំងពីឆ្នាំ២០០៧ មកម្លេះ ដោយរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយសំបុត្រអាពាហ៍ពិពាហ៍លេខ ២៧ សៀវភៅអាពាហ៍ពិពាហ៍លេខ១/២០១៧ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ។ ក្នុងអំឡុងពេលរួមរស់នៅជាមួយគ្នាតែងតែមានភាពការកូស មិនចុះសម្រុងគ្នា ដោយភាគីចុងចម្លើយចូលចិត្តផឹកស៊ី និងបានប្រើអំពើហិង្សាមកខ្លួនដែលជាប្រពន្ធ មិនត្រឹមតែប៉ុណ្ណោះចុងចម្លើយតែងតែធ្វើបាបផ្លូវចិត្តខ្លួន ចុងចម្លើយមិនដែលបានរកស៊ីចិញ្ចឹមកូន ដោយចុងចម្លើយចូលចិត្តលេងល្បែងស៊ីសង ។ ក្នុងអំឡុងពេលរៀបការជាមួយគ្នា មិនមានទ្រព្យសម្បត្តិរួមអ្វីនោះ គឺមានតែកូនបីនាក់នោះទេ ។

### ការអះអាងរបស់ចុងចម្លើយ

- ភាគីចុងចម្លើយឈ្មោះ [redacted] បូរិន បានអវត្តមាន គ្រប់ដំណាក់កាល ចុងចម្លើយឈ្មោះ [redacted] បូរិន បានទទួលដីកាកោះហៅរបស់តុលាការត្រឹមត្រូវតាមនីតិវិធី តែដល់ថ្ងៃកំណត់ចូលបែរជាភាគីចុងចម្លើយអវត្តមាន ដោយគ្មានមូលហេតុ ហើយក៏មិនបានដាក់ពាក្យសុំពន្យានីតិវិធី ។

### ភស្តុតាងសំអាងរបស់ដើមចោទ

- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ២៧ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧
- សំបុត្របញ្ជាក់កំណើតរបស់ដើមចោទឈ្មោះ [redacted] ស៊ីណាន
- សំបុត្របញ្ជាក់កំណើតកូនឈ្មោះ [redacted] គីមឡាង ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨
- សំបុត្រកំណើតកូនឈ្មោះ [redacted] វ៉ាន់នីឡា ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤
- សំបុត្រកំណើតកូនឈ្មោះ [redacted] លីម៉ី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥
- កិច្ចព្រមព្រៀងសន្យាឈប់ប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩

## ចំណុចមានវិវាទ

. គ្មាន ។

## សំអាងហេតុ

១. ពាក្យបណ្ដឹងរបស់ដើមចោទធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ សាលាដំបូងខេត្តសៀមរាបមានសមត្ថកិច្ចអាចទទួលដោះស្រាយ និងវិនិច្ឆ័យបណ្ដឹងនេះបានតាមមាត្រា៣ និងមាត្រា៩ នៃច្បាប់ស្ដីពីនីតិវិធីទាក់ទងនិងឋានៈបុគ្គលដែលត្រូវបានប្រកាស់ឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ ចុះថ្ងៃទី០៨.០៦.២០១០ និងយោងតាមមាត្រា១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២.ដើមចោទឈ្មោះ [redacted] ស៊ីណាន និងចុងចម្លើយឈ្មោះ [redacted] បូរិន បានរៀបអាពាហ៍ពិពាហ៍ដោយបានជូនដំណឹងជាសាធារណៈ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រឹមត្រូវស្របតាមមាត្រា ៩៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីហេតុនេះគូភាគីមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

៣.តាមការអះអាងរបស់ដើមចោទបានបញ្ជាក់ថាចុងចម្លើយតែងតែលេងល្បែងស៊ីសង និងមិនព្រមកែខ្លួន មិនត្រឹមតែប៉ុណ្ណោះចុងចម្លើយតែងប្រើអំពើហិង្សាមកលើដើមចោទ ជាហេតុធ្វើអោយដើមចោទមិនអាចបន្តរួមរស់នៅជាមួយគ្នាជាប្ដីប្រពន្ធតទៅទៀតបានឡើយ ។ ឃើញថាដើមចោទអស់មនោសញ្ចេតនាពីចុងចម្លើយ និងពុំមានឆន្ទៈចង់រួមរស់ជាមួយគ្នា បន្តទៅទៀតឡើយ។

៤.ភាគីចុងចម្លើយអវត្តមាន គ្រប់តំណាក់កាល ដោយភាគីចុងចម្លើយបានទទួលដីកាកោះហៅពីតុលាការត្រឹមត្រូវតាមនីតិវិធី តែដល់ថ្ងៃកំណត់ចូលភាគីចុងចម្លើយមិនបានចូលតាមការកំណត់របស់តុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការសន្មត់ថាភាគីចុងចម្លើយទទួលស្គាល់ការទាមទាររបស់ដើមចោទ ។

៥. នាពេលទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទនៅតែស្នើសុំការទាមទារដូចក្នុងពាក្យបណ្ដឹងចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ។

៦. ដើមចោទសុំសិទ្ធិធ្វើអំណាចមេបាលើកូនស្រីបីនាក់ កូនទី១ ឈ្មោះ [redacted] គីមឡាង ភេទស្រី កើតថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ១៧១ សៀវភៅកំណើតលេខ ០២ /២០១០ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១០ , កូនទី២ ឈ្មោះ [redacted] វ៉ាន់នីឡា ភេទស្រី កើតថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ដែលមានសំបុត្រកំណើតលេខ ៣៤ សៀវភៅកំណើតលេខ ០១/២០១៤ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ និងកូនទី៣ឈ្មោះ [redacted] លីមុី ភេទស្រី កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០១៥ ដែលមានសំបុត្រកំណើតលេខ ១០៥ សៀវភៅកំណើតលេខ ០៣/២០១៥ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ ។

៧. ចំពោះទ្រព្យសម្បត្តិរួម និងបំណុល ដើមចោទអះអាងថាមិនមាននោះទេ។

ឆ្លងតាមការពិនិត្យ ភស្តុតាង ការសាកសួរសាមីភាគីដើមចោទ ឃើញថាកូនស្រីទាំងបីនាក់ខាងលើ ពិតជាកូនរបស់ដើមចោទ និងចុងចម្លើយ ហើយបច្ចុប្បន្នកំពុងរស់នៅជាមួយដើមចោទ ។ ដើមចោទបានបង្ហាញឲ្យឃើញនូវចេតនាល្អ និងឆន្ទៈក្នុងការគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សាកូន និងអប់រំកូន ដែលអាចធានាដល់ឧត្តមប្រយោជន៍សម្រាប់កូន ឃើញថាការទាមទាររបស់ដើមចោទមានលក្ខណៈស្របតាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។



Scanned with CamScanner

៧. គប្បីតុលាការសម្រេចបន្ថែមអំពីសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនស្រីទាំងបីនាក់លើស្របតាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី បើទោះបីជាភាគីពុំបានទាមទារក៏ដោយ។

៧.គប្បីឲ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តីតាមការស្នើសុំរបស់ដើមចោទ ។

## សេចក្តីសម្រេចបញ្ចប់

១/. ឲ្យដើមចោទឈ្មោះ [redacted] ស៊ីណាន និងចុងចម្លើយឈ្មោះ [redacted] បូរិន លែងលះចាប់ពីពេលនេះតទៅ ។

២/. ប្រគល់អំណាចមេបា (សិទ្ធិ និងករណីកិច្ចគ្រប់គ្រង ចិញ្ចឹមបីបាច់ ថែរក្សា អប់រំ និងមើលការខុសត្រូវលើកូនជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន) លើកូនស្រីបីនាក់ កូនទី១ ឈ្មោះ [redacted] គីមឡាង ភេទស្រី កើតថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ១៧១ សៀវភៅកំណើតលេខ ០២ /២០១០ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១០ , កូនទី២ ឈ្មោះ [redacted] វ៉ាន់នីឡា ភេទស្រី កើតថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ដែលមានសំបុត្រកំណើតលេខ ៣៤ សៀវភៅកំណើតលេខ ០១/២០១៤ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៤ និងកូនទី៣ឈ្មោះ [redacted] លីម៉ី ភេទស្រី កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ដែលមានសំបុត្រកំណើតលេខ ១០៥ សៀវភៅកំណើតលេខ ០៣/២០១៥ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥៣ ឲ្យទៅដើមចោទ ។

៣/. ចុងចម្លើយបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព រហូតដល់កូនគ្រប់នីតិភាព។

៤./ ឲ្យចុងចម្លើយជាឪពុកមានសិទ្ធិសួរសុខទុក្ខ និងប្រាស្រ័យទាក់ជាមួយកូនកូនបានក្នុងមួយសប្តាហ៍ម្តង នៅរៀងរាល់ចុងសប្តាហ៍នីមួយៗ ។ ដើមចោទជាម្តាយត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ទំនាក់ទំនងនេះ ស្របតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

៥/.ឲ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តី តាមការទាមទារ។

សាលក្រមនេះបានទាញហេតុផល និងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និងកំបាំងមុខចុងចម្លើយ ទុកសិទ្ធប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ចៅក្រម



[redacted]